# PROFILE 2013

Vital®
Premium Water

មោទនភាពផលិតផលជាតិ



# ក្រុមហ៊ុនដំបូងបង្អស់ដែលទទួលបានវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ គ្រប់គ្រងគុណភាព អនុវត្តផលិតកម្មល្អ សុវត្ថិភាពម្ហូបអាហារ និងប្រព័ន្ធគ្រប់គ្រងបរិស្ថាន




CERTIFICATE

ISO 9001, ISO 14001, GMP, and HACCP Food Safety System

ISO 9001 CERTIFIED · ISO 14001 CERTIFIED · GMP CERTIFIED · HACCP CERTIFIED



# វីតាល់®

ទឹកពិសាគុណភាពខ្ពស់

ប្រភពស្រស់ថ្លានៃជីវិត

## មោទនភាពផលិតផលជាតិ

ទទួលស្គាល់ដោយ :

ក្រសួងសុខាភិបាល

ក្រសួងទេសចរណ៍

Institute of Standards of Cambodia

CORPORATION

CS 009: 2005
048-1ISC



Photo: GPPIC

# សារលិខិតលោកជំទាវនាយិកាប្រតិបត្តិក្រុមហ៊ុន

*សម្តេចទ្រង់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ជាទីគោរព និងជាទីមេត្រី!*

រយៈពេលជាង ០២ ឆ្នាំមកនេះ ទឹកបរិសុទ្ធ វីតាល់® បានក្លាយខ្លួនជាផលិតផលជាតិឈានមុខគេ ដែលទទួលបានការពេញនិយមចូលចិត្ត និងគាំទ្រយ៉ាងទូលំទូលាយពីសំណាក់ប្រជាពលរដ្ឋគ្រប់ស្រទាប់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ នេះគឺជាសក្ខីភាពដែលឆ្លុះបញ្ចាំងអោយឃើញនូវនិន្នាការដែលប្រជាពលរដ្ឋយើងមានការយល់ដឹងកាន់តែស៊ីជម្រៅពីសារប្រយោជន៍នៃការពិសាទឹកដែលមានគុណភាពខ្ពស់ ព្រមទាំងចាប់ផ្តើមទទួលស្គាល់អោយតម្លៃ និងជឿទុកចិត្តលើស្នាដៃផលិតផលក្នុងស្រុកផងដែរ។

សុខភាពល្អ ជាទ្រព្យសម្បត្តិដ៏មហាសាលមិនអាចកាត់ថ្លៃបាន។ ការពិសាទឹកគុណភាពល្អជាប្រចាំ និងធ្វើលំហាត់ប្រាណទៀងទាត់គឺជាគន្លឹះដ៏ស័ក្តិសិទ្ធិមួយសម្រាប់ជួយធ្វើអោយសុខភាពយើងស្រស់ថ្លារឹងមាំជានិច្ច។ វាជាមូលហេតុចម្បងដែលជំរុញអោយក្រុមហ៊ុន **អិនវីស៊ី ខបភើរេសិន** បន្តខិតខំប្រឹងប្រែងធ្វើយ៉ាងណាផ្តល់ជូនជនរួមជាតិគ្រប់រូបនូវទឹកពិសាដែលមានគុណភាពខ្ពស់ដើម្បីនាំមកនូវសុខុមាលភាព និងភាពស្រស់ថ្លាក្នុងជីវិតប្រចាំថ្ងៃ។ ទន្ទឹមនឹងនេះ វីតាល់® ក៏បានចូលរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រផងដែរ។ ជាក់ស្តែង វីតាល់® បានបន្តបរិច្ចាគប្រាក់ចំណូលរបស់ខ្លួន (២៥ រៀលពីការលក់ទឹកបរិសុទ្ធ វីតាល់® ០១ ដប) ដើម្បីឧបត្ថម្ភគាំទ្រដល់សកម្មភាពសង្គម និងការងារមនុស្សធម៌នានាជាច្រើន។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ដែលបានបន្តគាំទ្រដល់ វីតាល់® រហូតរៀងមក។ សន្តានចិត្តដ៏ប្រពៃនេះបាននិងកំពុងជំរុញអោយ វីតាល់® បន្តប្រឹងប្រែងអោយអស់ពីសមត្ថភាពដើម្បីបម្រើប្រជាជន និងសង្គមជាតិទាំងមូលជានិច្ចនិរន្តរតរៀងទៅ។

សូមអរព្រះគុណ និង អរគុណ!

លោកជំទាវឧកញ៉ា **ជឹង សុគន្ធាវី**
**នាយិកាប្រតិបត្តិក្រុមហ៊ុន**

# Message from Executive Director



*Excellencies, Ladies and Gentlemen!*

Over the past two years, Vital® Premium Water has emerged as a leading local product in the Kingdom of Cambodia consumed by people from all walks of life. Cambodian people are starting to appreciate the importance of high quality drinking water, and they value and trust their local products. They prefer Vital®.

"Health is our most valuable asset". Drinking high quality water and doing regular exercises are keys to good health. That's why **NVC Corporation** offers the highest quality of drinking water. Vital®'s growth contributes to our economic development. NVC is actively participating in poverty reduction by donating part of its income (25 riels from each bottle sold) to support social and humanitarian activities.

On behalf of NVC Corporation, I would like to express my profound gratitude for your constant support which inspires Vital® to continue doing its best to serve the people and society as a whole.

Thank you.

Lok Chumteav Oknha **CHOEUNG SOKUNTHEAVY**
**Executive Director**



ទឹកបរិសុទ្ធ វីតាល់® ជាផលិតផលរបស់ក្រុមហ៊ុន អិនវីស៊ី ខបភើរេសិន ដែលជាសាជីវកម្មជាតិស្របច្បាប់ វិនិយោគក្នុងវិស័យម្ហូបអាហារ និងភេសជ្ជៈនៅប្រទេសកម្ពុជា ។ រោងចក្រផលិតទឹកបរិសុទ្ធ វីតាល់® ត្រូវបានសម្ពោធដាក់អោយដំណើរការជាផ្លូវការ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០១០ ស្របពេលដែលប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសប្រារព្ធពិធីរំលឹកខួបជ័យជំនះ ៧ មករា ។







Vital® Premium Water is a product of **NVC Corporation Ltd.,** a food and beverage manufacturer duly registered with the Cambodian Ministry of Commerce. Vital®'s factory was launched on January 7, 2010, coinciding with the celebration of the Liberation Day nationwide.

# វីតាល់®   Vital®



វីតាល់® ផ្សំមកពីពាក្យ (វីរ) + (តាលុជ:)។
វីរ មានន័យថា មាំមួនរឹងប៉ឹង ក្លាហាន មោះមុត ខ្លាំងពូកែ ជាពិសេសជនជាតិខ្មែរតែងតែមានវីរភាពខ្ពស់ជានិច្ច។

តាល់ មកពីពាក្យ តាលុជ: ជាសំឡេងខ្ទរ ចេញពីក្រអូមមាត់មនុស្ស ដូចជាភាពល្បីរន្ទឺ របស់ជាតិខ្មែរយើង ដែលលឺខ្ទរខ្ទារ ខ្ទរខ្ទាយ តាំងពីបូរាណកាលមក ជាពិសេសស្នាដៃកេរដំណែល តាំងពីដូនតាដ៏អស្ចារ្យ។

Vital® is a combination of “Vitalize and Talent”

**Vitalize** means to endow with life, to make lively or vigorous. Water vitalizes our bodies, keeping us fresh and strong.

**Talent** means a special aptitude or faculty. Cambodians are an artistic and creative people with great talent. Our amazing heritage, in which we all take pride, shows this.

វីតាល់® មានអត្ថន័យជ្រាលជ្រៅ និងមានតំលៃជាសកលទាំងភាសាជាតិ និងអន្តរជាតិ។
ស្លាកសញ្ញា វីតាល់® គឺជានិមិត្តរូបទឹកពិសាដែលមានគុណភាពខ្ពស់ ដែលជាប្រភពស្រស់ថ្លានៃជីវិត និងជា មោទនភាពផលិតផលជាតិ។
ពាណិជ្ជសញ្ញា វីតាល់® ត្រូវបានចុះបញ្ជីស្របច្បាប់នៅក្រសួងពាណិជ្ជកម្មនៃប្រទេសកម្ពុជា

The term is very meaningful for both Khmer and English. Vital® Brand symbolizes the premium quality of drinking water in the country. It is the source of bright life and manifests "**Khmer Product Khmer Pride**". The Vital® trademark is duly registered with the Ministry of Commerce.





# មោទនភាពផលិតផលជាតិ!

ទឹកបរិសុទ្ធ វីតាល់® គឺជាផលិតផលឈានមុខគេដែលមានអតិថិជនរាប់លាននាក់មកពីគ្រប់ស្រទាប់វណ្ណៈ និយមចូលចិត្ត និងគាំទ្រយ៉ាងទូលំទូលាយ។

លើសពីនេះទៅទៀត វីតាល់® គឺជាទឹកបរិសុទ្ធក្នុងស្រុកដំបូងគេដែលត្រូវបាននាំចេញទៅកាន់បរទេស (ប្រទេសជប៉ុន) និងត្រូវបានជ្រើសរើសដោយកងទ័ពមូលដ្ឋានសមុទ្រសហរដ្ឋអាមេរិក នៅក្នុងបេសកកម្មមនុស្សធម៌ កាលពីខែធ្នូ ឆ្នាំ២០១១។ សក្ខីភាពនេះ គឺជាមោទនភាពផលិតផលជាតិ!

KHMER PRODUCT,

# National Pride!

Vital® Premium Water is widely preferred and consumed by millions of local people from all walks of life.

Vital® is the first local bottled water to be exported to Japan.

Vital® was selected exclusively by the US marines during their humanitarian mission in Cambodia in December, 2011.

We are proud of our national product!

KHMER PRIDE!








# មោទនភាពនឹងជោគជ័យយើង!

ថ្វីត្បិតតែមានអាយុក្មេងខ្ចីជាងគេក្នុងចំណោមទឹកបរិសុទ្ធក្នុងស្រុកទាំងអស់ក៏ដោយ ឆ្លងតាមរយៈកិច្ចប្រឹងប្រែងផ្នែកគុណភាព សោភ័ណភាព សេវាកម្ម និងការចូលរួមចំណែកក្នុងសង្គម វីតាល់® ទទួលបានជោគជ័យដ៏ត្រចះត្រចង់ដោយបានក្លាយខ្លួនទៅជាទឹកបរិសុទ្ធឈានមុខគេនៅក្នុងប្រទេសកម្ពុជា។ ជាក់ស្តែងនៅក្នុងរយៈពេល ០២ ឆ្នាំតែប៉ុណ្ណោះ វីតាល់® បានវិវឌ្ឍន៍ខ្លួនពីក្រុមហ៊ុនមួយដែលមានបុគ្គលិក ៣០ នាក់ ទៅជាក្រុមហ៊ុនទ្រង់ទ្រាយធំមួយដែលមានបុគ្គលិករហូតដល់ទៅ ២០០ នាក់ ជាងនេះទៅទៀត សមត្ថភាពផលិតរបស់យើងបានកើនឡើងពី ៦០.០០០ លីត្រ ក្នុងមួយថ្ងៃ ដល់ ១៨០.០០០ លីត្រ ក្នុងមួយថ្ងៃដើម្បីបំពេញតម្រូវការចែកចាយដែលគ្របដណ្តប់ទាំង ២៤ រាជធានី-ខេត្ត។



# We are **Proud** of Our **SUCCESS!**

Vital® has emerged as the leading bottled water in Cambodia in two short years, despite being one of the local bottled water industry's newest players. Our efforts to improve the quality, brand awareness and service, plus our attention to social responsibility has led us to expand production from 60,000 liters to 180,000 liters a day. From an initial staff of 30, we now employ 200 people to meet the demand. Distribution is now in every city-province nationwide.



# មោទនភាពនឹងសមិទ្ធផលថ្មី!

អបអរសាទរសមិទ្ធិផលថ្មីរបស់ វីតាល់® ។ ដើម្បីឆ្លើយតបតាមតម្រូវការរបស់អតិថិជនអោយបានកាន់តែរហ័សទាន់ចិត្ត ក្រុមហ៊ុនបានសាងសងអាគាររោងចក្រថ្មី បំពាក់ទៅដោយសង្វាក់ផលិតកម្មទំនើប ដែលប្រើប្រាស់នូវបច្ចេកវិទ្យាចុងក្រោយគេបង្អស់នៅលើផ្ទៃដីទំហំជាង ១០ ០០០ ម៉ែត្រការ៉េ ជាមួយនឹងសមត្ថភាពផលិតខ្ពស់ជាងមុន ៣ ដង ។





# Our FACTORY!

To cater to the increasing demand, we have constructed a new factory compound that is in excess of 10,000 square meters. This factory is fully equipped with new state-of-the art equipment and technology. With this new factory, Vital®'s production will increase threefold.




# មោទនភាពនឹងទឹកពិសាគុណភាពខ្ពស់!

គុណភាពជាចម្បង គឺជាគោលការណ៍ និងគុណតម្លៃរបស់យើង។

វីតាល់® ផលិតតាមបទដ្ឋានបច្ចេកទេសអន្តរជាតិ ហើយទទួល បានវិញ្ញាបនបត្រ ISO 9001 និង ISO 14001។



## CERTIFICATE

ISO 9001, ISO 14001, GMP, and HACCP Food Safety System




PROUD OF HIGH-QUALITY DRINKING WATER!

We take pride in providing highest-quality drinking water!
Quality is our core principle and value. Vital product conforms to ISO 9001 and ISO 14001.

# មោទនភាពនឹងសុខភាពស្រស់ថ្លា!

សុខភាពល្អ គឺជាទ្រព្យសម្បិត្តដ៏មហាសាលដែលមិនអាចកាត់ថ្លៃបាន។ ពិសាទឹកគុណភាពខ្ពស់ជាប្រចាំ និងហាត់ប្រាណទៀងទាត់ ជាគន្លឹះដ៏ស័ក្តិសិទ្ធិមួយសម្រាប់ជួយធ្វើអោយសុខភាពយើងស្រស់ថ្លារឹងមាំជានិច្ច។



# We Promote **GOOD HEALTH**

"Health is our most valuable asset".
Drinking high quality water and doing regular exercises are keys to good health.






# មោទនភាពដោយបាន
# បំរើជាតិមាតុភូមិយើង !

យុទ្ធជនខ្មែរដ៏អង់អាចក្លាហាន បានការពារបូរណភាពដែនដីដ៏បវរនៃមាតុភូមិយើង។ក្នុងនាមជាកូនខ្មែរយើងពិតជាមានមោទនភាពនិងស្ញប់ស្ញែងយ៉ាងខ្លាំងចំពោះគំរូវីរភាពដ៏ថ្លៃថ្លានេះ។ ថ្វីត្បិតមិនបានបំពេញភារកិច្ចនេះដោយផ្ទាល់ក៏ដោយ វីតាល់® បានឧបត្ថម្ភប្រាក់ ៨០០០ដុល្លារ ដល់សមរភូមិមុខ តាមរយៈមូលនិធិបាយ័ន កាលពីខែមករា ឆ្នាំ២០១១។



## WE ARE PROUD TO PROTECT OUR TERRITORIAL INTEGRITY!

Our men stand courageously protecting our territorial integrity. As Cambodians, we are proud of their heroic acts. We're not at the frontline, but we show our support. Vital® has donated USD 8,000 through the Bayon Foundation in January, 2011.




បរិស្ថានល្អចាប់ផ្តើមពីខ្ញុំ! វីតាល់® រួមចំណែកដើម្បីអោយប្រទេសកម្ពុជាមានធម្មជាតិស្រស់បំព្រងគ្រប់រដូវកាល!











Good environment starts from each of us! Vital® helps make Cambodia a greener place to live!


A+



# ស្នាមញញឹម ដោយមោទនភាពនឹងការងាររបស់យើងទាំងអស់គ្នា!

ជោគជ័យដ៏ធំធេងរបស់ វីតាល់® កើតចេញពីការខិតខំប្រឹងប្រែងយកចិត្តទុកដាក់យ៉ាងស្វិតស្វាញ ពីសំណាក់សមាជិកគ្រប់រូបនៃក្រុមការងារយើងទាំងមូល។ ចាប់តាំងពីគណៈគ្រប់គ្រងរហូតដល់ បុគ្គលិក កម្មករ គឺសុទ្ធតែបានប្រឹងអស់កម្លាំងកាយចិត្ត ដើម្បីបម្រើនូវសេចក្តីត្រូវការរបស់ អតិថិជន។ យើងទាំងអស់គ្នាពិតជាមានមោទនភាពក្រៃលែងចំពោះការងារប្រចាំថ្ងៃរបស់យើង ព្រោះវាបានជួយបំរើអត្ថប្រយោជន៍ប្រជាពលរដ្ឋ និងសង្គមជាតិទាំងមូល។



We believe that our team's effort and attention to detail are the driving force behind the success of Vital®. We all share great enthusiasm and commitment to satisfying our customers' needs. We take great pride in the work we perform each day as it serves our people and the nation.

# ស្នាមញញឹមដោយមោទនភាពបន្ទាប់ពីបានបរិច្ចាគឈាមសម្រាប់សង្គ្រោះជីវិតជនរួមជាតិជាទីស្រឡាញ់!

វីតាល់® គឺជាសកម្មជនឈានមុនគេដែលចូលរួមដឹកនាំគាំទ្រយុទ្ធនាការបំផុសចលនាបរិច្ចាគឈាម
ស្របតាមសេចក្តីអំពាវនាវដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។







## We smile with pride and donate our blood!

Vital® is a leading activist organizing and supporting the blood donation campaign across the country following the appeal made by **Samdech Akka Moha Sena Padei Techo Hun Sen**, Prime Minister of the Kingdom of Cambodia.




*She is smilling; she is proud of her blood donation!*

# ស្នាមញញឹមដោយមោទនភាពចំពោះសមិទ្ធផលនៃថវិកា ២៥៛ របស់ជនរួមជាតិ ដែលជាអតិថិជនរបស់ វីតាល់® បានចាប់មគ្គផលកុសលបុណ្យទាំងអស់គ្នា!



ប្រគេនរថយន្ត ១៥ កៅអី ចំនួន ២ គ្រឿង ដល់ពុទ្ធិកសិក្សាជាតិ








Vital® has contributed two 15-seat vans to the National Institute of Buddhist Studies.

We also smile proudly for the good that we can do together thanks to the 25 riel per-bottle contribution from each and every Vital® customer.

# ស្នាមញញឹមដោយមោទនភាព ចំពោះទង្វើប្រកបដោយគុណធម៌របស់ជនជាតិខ្មែរយើង!







ជនជាតិខ្មែរយើងមានពាក្យមួយឃ្លាពោលថា "ជួយគ្នាទាន់គ្រាក្រ "។ វីតាល់® បាននិងកំពុងបន្តលើកតម្កើងវប្បធម៌នៃការចែករំលែក ជួយឧបត្ថម្ភ គាំពារ សង្គ្រោះគ្នាក្នុងគ្រាមានគ្រោះអាសន្នផ្សេងៗ ដែលជាទំនៀមទម្លាប់ប្រពៃណីតាំងពីបុរាណកាលមក។

There's a Khmer expression, "Help others in need."
Our culture of sharing, helping, supporting, protecting and rescuing one another in times of need is a tradition that dates back centuries and has been continuously upheld by Vital®





## ស្នាមញញឹមប្រកបដោយក្តីសង្ឃឹមនេះ អាចមានតទៅទៀតបាន គឺអាស្រ័យលើទឹកចិត្តសប្បុរសរបស់យើងទាំងអស់គ្នា!

ការពិសាទឹកបរិសុទ្ធ វីតាល់® មិនត្រឹមតែផ្តល់ភាពស្រស់ថ្លាដល់ជីវិតប្រចាំថ្ងៃប៉ុណ្ណោះទេ វាថែមទាំងផ្តល់ឱកាសអោយអតិថិជនចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងការកាត់បន្ថយភាពក្រីក្រទៀតផង។ ពិសាទឹក វីតាល់® ០១ ដប មានន័យថា អ្នកបានចូលរួមបរិច្ចាគទឹកប្រាក់ចំនួន ២៥ រៀល សម្រាប់យកទៅជួយឧបត្ថម្ភដល់ការងារមនុស្សធម៌ និងសកម្មភាពអភិវឌ្ឍសង្គមជាតិនានា។ តាមរយៈនេះ វីតាល់® បានឧបត្ថម្ភដល់កុមារកំព្រា និងសិស្សខ្វះ លទ្ធភាពនៅគំនរសម្រាមស្ទឹងមានជ័យចំនួន ៣.០០០.០០០ រៀលរួចមកហើយ។



## These Smiles of Hope Need Your SUPPORT!

Drinking Vital® premium water helps support a healthy life and provides the opportunity to contribute to our economic development. With each bottle of Vital® premium water you drink, you are donating 25 riels to support various social and humanitarian activities and poverty reduction. Through this initiative, Vital® has so far donated 3,000,000 riels to orphans and impoverished students at the Stoeung Meanchey dump site.


វីតាល់
ទឹកពិសាគុណភាពខ្ពស់
សមិទ្ធផលនៃ
២៥៩
ចូលរួមជាមួយ វីតាល់
ដើម្បីបំរើសកម្មភាពត


ប័ណ្ណថ្លែងអំណរគុណ
ប្រធានកាកបាទក្រហមកម្ពុជា
សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ
ទឹកពិសាវីតាល់
ក្រុមហ៊ុន អិន_វី_ស៊ី
ដែលបានជួយឧបត្ថម្ភថវិកាចំនួន 10,000 ដុល្លារអាមេរិក
អបអរខួប ១៤៧ ទិវាពិភពលោក កាកបាទក្រហម អឌ្ឍចន្ទក្រហម ក្រោមប្រធានបទៈ "សង្គ្រោះជីវិត ផ្លាស់ប្តូរផ្នត់គំនិត"
ប្រព្រឹត្តទៅនៅថ្ងៃទី ០៨ ឧសភា ២០១០ នៅទីស្នាក់ការកណ្តាល កាកបាទក្រហមកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។
ពរ បវរសួស្តីមហាប្រសើរ និងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។
: ០២៣៥/១០ កក្រក.១១
ភ្នំពេញ ថ្ងៃទី ខែ ឧសភា ឆ្នាំ ២០១០
សប្បុរសជន
០១០
ប៊ុន រ៉ានី ហ៊ុនសែន


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ក្រសួងសុខាភិបាល
មជ្ឈមណ្ឌលជាតិផ្តល់ឈាម
រដ្ឋមន្ត្រីក្រសួងសុខាភិបាល
សូមថ្លែងអំណរគុណជាអនេកប្បការជូនចំពោះ លោកជំទាវ ជឹង សុគន្ធារី នាយិកាប្រត្តិបត្តិ ក្រុមហ៊ុន NVC Corporation Vital ដែលបានរៀបចំពិធី បរិច្ចាគឈាម ជូនដល់មជ្ឈមណ្ឌលជាតិផ្តល់ឈាម បានចំនួន ២៨លើក និងមានសប្បុរសជនផ្តល់ឈាមចំនួន ២៨៤៥ នាក់ ដើម្បីជាគុណប្រយោជន៍ក្នុងការជួយសង្គ្រោះជីវិត
ភ្នំពេញ, ថ្ងៃទី ១១ ខែ មិ
រដ្ឋមន្ត្រី
ម៉ម_ប៊ុ


ប័ណ្ណថ្លែងអំណរគុណ
ប្រធានកាកបាទក្រហមកម្ពុជា
សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ
NVC Corporation
ដែលបានជួយឧបត្ថម្ភថវិកាចំនួន 10,000 ដុល្លារអាមេរិក
អបអរខួបទី ១៤៨ ទិវាពិភពលោក កាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា
ប្រព្រឹត្តទៅនៅថ្ងៃទី ០៣ ឧសភា ២០១១ នៅទីស្នាក់ការកណ្តាល កាកបាទក្រហមកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។
សូមប្រសិទ្ធពរ បវរសួស្តីមហាប្រសើរ និងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។
ចុះបញ្ជីលេខៈ ០៤២០/១១ កក្រក.១១
ភ្នំពេញ ថ្ងៃទី ខែ ឧសភា ឆ្នាំ ២០១១
កក្រក សប្បុរសជន ២០១១
ប៊ុន រ៉ានី ហ៊ុនសែន



Vital®
Premium Water

**Source of Healthy Life**


អាគារលេខ ៨៨៨K ផ្លូវលេខ ៥៩៨ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទូរស័ព្ទ : ០២៣ ៨៦៤ ២២២ / ៨៦៤ ៣៣៣
ទូរសារ : ០២៣ ៨៦៤ ៩៩៩
គេហទំព័រ : www.vitalpremiumwater.com
អ៊ីមែល : info@vitalpremiumwater.com






Photos: Vital, Graphic Roots, GPPIC
Designed by Graphic Roots - www.graphicroots.net